# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

៚៚✧៛៛

# ផែនការគ្រប់គ្រង
## សហគមន៍តំបន់ការពារធម្មជាតិ ព្រាំងចំការក្រោម
## នៃតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង ភូមិចំការក្រោម ឃុំស្រែអំបិលនិង
## ភូមិព្រាំង ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង
## ( ឆ្នាំ ២០២៥-២០២៩ )



សម្របសម្រួលដោយ មន្ទីរបរិស្ថានខេត្តកោះកុង និងអង្គការមរតក

ឆ្នាំ ២០២៥

**មាតិកា**

**១-សេចក្តីផ្តើម**......១
**២-ទស្សនៈវិស័យ និងគោលបំណង**......២
២.១-ទស្សនៈវិស័យផែនការគ្រប់គ្រង......២
២.២-គោលបំណង......២
**៣-ស្ថានភាពសេដ្ឋកិច្ចសង្គម**......២
៣.១-ស្ថិតិសមាជិកសហគមន៍......៣
៣.២-មុខរបរ សមាជិកសហគមន៍......៤
៣.៣-សមិទ្ធផលសំខានៗដែលសហគមន៍សម្រេចបានកន្លងមក......៤
៣.៤-បញ្ហាប្រឈមកំពុងជួបប្រទះ......៤
**៤-ស្ថានភាពធនធានព្រៃសហគមន៍**......៥
៤.១-ស្ថានភាពព្រៃសហគមន៍......៥
៤.២-ទីតាំង និងទំហំព្រៃសហគមន៍......៥
៤.៣-វិធីសាស្ត្រ និងលទ្ធផលនៃការធ្វើសារពើភ័ណ្ឌព្រៃសហគមន៍......៦
៤.៤-ស្ថានភាពនៃការប្រើប្រាស់ផល_អនុផលព្រៃឈើ......៦
**៥-យុទ្ធសាស្ត្រនៃការគ្រប់គ្រង**......៧
៥.១-រចនាសម្ព័ន្ធគ្រប់គ្រង......៧
៥.២-ការបែងចែកតំបន់គ្រប់គ្រង......៧
៥.៣-គោលការណ៍ប្រើប្រាស់ផល_អនុផលព្រៃឈើ......៨
៥.៤-គោលការណ៍បែងចែកផលប្រយោជន៍......៩
៥.៥-ការអភិវឌ្ឍអាជីវកម្មខ្នាតតូចក្នុងសហគមន៍......៩
**៦-ផែនការអភិវឌ្ឍន៍សម្រាប់៥ឆ្នាំ និងផែនការអនុវត្តន៍ប្រចាំឆ្នាំនីមួយៗ**......១០
៦.១-តារាងផែនការសហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោម(២០២៥-២០២៩)......១០
៦.២-យន្តការត្រួតពិនិត្យវាយតម្លៃ......១៧
**៧-តារាងឧបសម្ព័ន្ធ**......២២
១-ប្រកាសទទួលស្គាល់របស់ក្រសួងបរិស្ថាន
២-ផែនទីសហគមន៍តំបន់ការពារធម្មជាតិកណ្តោល
៣-ផែនទីបែងចែកតំបន់គ្រប់គ្រង
៤-តារាងបញ្ជីឈ្មោះអ្នកចូលរួមពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធថ្នាក់ឃុំនិងសហគមន៍
៥-តារាងបញ្ជីឈ្មោះអ្នកចូលរួមពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធថ្នាក់ស្រុកនិងសហគមន៍

## ១.សេចក្តីផ្តើម

សហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោម ស្ថិតក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងដង ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៨ដោយការស្ម័គ្រចិត្តពីប្រជាពលរដ្ឋចំនួនពីរភូមិគឺភូមិចំការក្រោម ឃុំស្រែអំបិល និងភូមិព្រាំង ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង ដោយមានការសម្របសម្រួលពីមន្ទីរបរិស្ថានខេត្តកោះកុង តំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង អាផ្ទាធរដែនដីនិង មានការជួយឧបត្ថម្ភពីអង្គការមេតេកប្រចាំស្រុកស្រែអំបិល។

សហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោមត្រូវបានប្រកាសទទួលស្គាល់ជាផ្លូវការតាមរយៈប្រកាសលេខៈ ០០៨ប្រក.ប/ស្ត ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៧ របស់ក្រសួងបរិស្ថាន សហគមន៍មាននេះផ្ទៃដី សរុបចំនួន ៨៥៩ហ.ត មានទីតាំងពីរចំណុចគឺ ចំណុចវាលធំមានផ្ទៃដីចំនួន ៧៥៨ហ.ត និងចំណុចពេជដោមានផ្ទៃដីចំនួន១០១ហ.ត ។ ក្នុងដំណើរការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោមបានរៀបចំរចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រងសហគមន៍ លក្ខន្តិកៈសហគមន៍ បោះបង្គោលព្រំដាក់ស្លាកសញ្ញា និងបានចូលរួមការងារល្បាតទប់ស្កាត់បទល្មើសធនធានធម្មជាតិក្នុងដែនសហគមន៍។ មិនតែប៉ុណ្ណោះសហគមន៍សម្រេចបានសមិទ្ធិផលមួយចំនួនដូចជា ការសាងសង់ស្នាក់ការសហគមន៍បានចំនួន១ខ្នង ទំហំ៥ម៉ែត្រគុណ៦ម៉ែត្រ ដែលគាំទ្រដោយអង្គការមេតេក បានមកពីម្ចាស់ជំនួយWWF អំណោយទូកពីសប្បុរសជនចំនួន១គ្រឿងនិងសម្ភារៈផ្សេងៗមួយចំនួនទៀតព្រមទាំងបានចាក់ដីបំពេញទីធ្លាខាងមុខស្នាក់ការសហគមន៍ចំនួន២០ឡាន។

ទោះបីសហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោម ទទួលបានសមិទ្ធិផលជាច្រើន និងបានខិតខំចូលរួមទប់ស្កាត់បទល្មើសការពារអេកិរក្សធនធានធម្មជាតិក្នុងដែនសហគមន៍ តែសហគមន៍ក៏នៅមានបញ្ហាមួយចំនួនកំពុងជួបប្រទះដូចជាការចូលរួមសមាជិកសហគមន៍និងសមត្ថភាពក្នុងការគ្រប់គ្រងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ កង្វះធនធានមនុស្ស និងសម្ភារៈសម្រាប់អនុវត្តការងាររបស់សហគមន៍ បទល្មើសធនធានធម្មជាតិក្នុងដែនសហគមន៍នៅតែមានកើតឡើងនៅឡើយ។

ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់របស់សហគមន៍ និងស្របតាមទិដ្ឋភាពច្បាប់ស្តីពីក្រមបរិស្ថាននិងធនធានធម្មជាតិក្នុងមាត្រា៣៧៤សហគមន៍តំបន់ការពារធម្មជាតិត្រូវរៀបចំផែនការគ្រប់គ្រងធនធានធម្មជាតិ ដោយមានការទទួលស្គាល់ពីថ្នាក់ក្រោមជាតិ។ ផែនការគ្រប់គ្រងធនធានធម្មជាតិ នៃសហគមន៍តំបន់ការពារធម្មជាតិត្រូវធ្វើសមាហរណកម្មជាមួយផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ ហេតុនេះហើយទើបសហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោមបានខិតខំរៀបចំផែនការគ្រប់គ្រងធនធានធម្មជាតិរយៈពេល៥ឆ្នាំ (២០២៥-២០២៩)ដោយមានការជួយឧបត្ថមគាំទ្រពីអង្គការមេតេក សហការជាមួយ មន្ទីរបរិស្ថានខេត្តកោះកុង បានរៀបចំផែនការគ្រប់គ្រងលើកទីមួយរបស់សហគមន៍។ សហគមន៍បានធ្វើការសិក្សាប៉ាន់ប្រមាណពីតម្រូវការប្រើប្រាស់ផល-អនុផលព្រៃឈើរបស់សមាជិកសហគមន៍ និងការសិក្សាប៉ាន់ប្រមាណធនធានធម្មជាតិព្រៃឈើនៅក្នុងសហគមន៍តាមរយៈការធ្វើសារពើភណ្ឌព្រៃឈើសហគមន៍។ លទ្ធផលនៃការសិក្សាទាំងនោះបានផ្តល់នូវព័ត៌មាននិងទិន្នន័យជាមូលដ្ឋានសម្រាប់ពិគ្រោះយោបល់ក្នុងការរៀបចំផែនការគ្រប់គ្រងរយៈពេលប្រាំឆ្នាំ(២០២៥-២០២៩)។

ផែនការគ្រប់គ្រងធនធានធម្មជាតិនេះ គឺជាសមិទ្ធផលថ្មីមួយទៀតរបស់សហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោម និងជាត្រីវិស័យចង្អុលបង្ហាញដល់កិច្ចការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍរបស់សហគមន៍។ លើសពីនេះទៀតផែនការគ្រប់គ្រងសហគមន៍នេះក៏ជាមធ្យោបាយមួយសម្រាប់ទាក់ទាញប្រភពថវិកាពីគម្រោង ដៃគូអភិវឌ្ឍន៍ ឬសប្បុរសជន ដែលបំណងជួយគាំទ្រក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍសហគមន៍ផងដែរ។

ម្យ៉ាងវិញទៀតផែនការគ្រប់គ្រងនេះ ពិតជានៅមានភាពខ្វះចន្លោះព្រោះថាជាផែនការលើកទី០១ដែលសហគមន៍ព្រាំងចំការក្រោមបានរៀបចំឡើង។ ហើយតាមរយៈផែនការគ្រប់គ្រងនេះសហគមន៍ពិតជាបានរៀនសូត្រ និងកែលម្អលើសកម្មភាពគ្រប់គ្រងធនធានធម្មជាតិក្នុងសហគមន៍ដោយផ្អែកតាមយន្តការត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំនីមួយៗ។

## ២.ទស្សនៈវិស័យ និងគោលបំណង

### ២.១.ទស្សនៈវិស័យនៃផែនការគ្រប់គ្រង

ការរៀបចំផែនការគ្រប់គ្រងរយៈពេល៥ឆ្នាំ (២០២៥-២០២៩) របស់សហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោម បានកំណត់នូវទស្សនៈវិស័យពោលគឺ អភិរក្សធនធានធម្មជាតិ នឹងធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់សមាជិកប្រកបដោយភាពសុខដុមរមនាក្នុងសហគមន៍។

ដើម្បីសម្រេចបាននូវទស្សនៈវិស័យនេះ សហគមន៍បានកំណត់នូវសកម្មភាពជាយុទ្ធសាស្ត្រសំខាន់ៗសម្រាប់ការអនុវត្តផែនការគ្រប់គ្រង (២០២៥-២០២៩) ដូចខាងក្រោម៖

- ស្តារគុណភាពព្រៃឡើងវិញ ដោយធ្វើការដាំកូនឈើមានតម្លៃបន្ថែមនៅតាមចន្លោះព្រៃ
- បង្កើនការធ្វើកសិរុក្ខកម្មជាលក្ខណៈគ្រួសារ (ដាំឈើហូបផ្លែ បន្លែ និងការចិញ្ចឹមមាន់)
- រៀបចំផ្តល់នូវសេវាកម្មទេសចរណ៍ធម្មជាតិ សម្រាប់បង្កើនប្រាក់ចំណូលក្នុងសហគមន៍
- បង្កើនសមត្ថភាពដល់សមាជិកសហគមន៍ជុំរុញឱ្យមានភាពជាម្ចាស់ក្នុងការគ្រប់គ្រងធនធានតាមរយៈការពង្រឹងអភិបាលកិច្ចល្អ។

### ២.២.គោលបំណង

ការរៀបចំផែនការគ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោម ធ្វើឡើងក្នុងគោលបំណងជាក់លាក់ ដូចខាងក្រោម៖

- កំណត់សកម្មភាពជាអាទិភាពសម្រាប់ការអនុវត្តការងារឱ្យចំទិសដៅក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍
- កំណត់នូវគោលការណ៍ដកហូត និងប្រើប្រាស់ឱ្យបានសមស្រប និងគោលការណ៍បែងចែកផលប្រយោជន៍ប្រកបដោយសមធម៌
- លើកកម្ពស់ប្រសិទ្ធភាពការគ្រប់គ្រង និងការអភិវឌ្ឍសហគមន៍ស្របតាមទិដ្ឋភាពច្បាប់ស្តីពីក្រមបរិស្ថាន និងធនធានធម្មជាតិ

ស្វែងរកដៃគូគាំទ្រនិងមូលនិធិសម្រាប់ការងារគ្រប់គ្រងនិងអភិវឌ្ឍន៍សហគមន៍។

## ៣. ស្ថានភាពសេដ្ឋកិច្ចសង្គម

### ៣.១ ស្ថិតិសមាជិកសហគមន៍

សហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោមបង្កើតឡើងមានពីរភូមិ ភូមិចំការក្រោម ឃុំស្រែអំបិល មានសមាជិកចូលរួមសរុបចំនួន៧៤៥នាក់ក្នុងនោះស្រី៣៨២នាក់ និងភូមិព្រាំង ឃុំដងពែងមានសមាជិក ចូលរួមសរុប៩៧៣នាក់ក្នុងនោះមានស្ត្រី៤៩១នាក់ (ទិន្នន័យឆ្នាំ២០២៣)។

តារាង: ស្ថិតិសមាជិកសហគមន៍ព្រាំងចំការក្រោម

| ភូមិ | ចំនួនគ្រួសារ | ចំនួនមនុស្ស | | សរុប |
|---|---|---|---|---|
| | | ប្រុស | ស្រី | |
| ភូមិចំការក្រោម ឃុំស្រែអំបិល | ១៥៩ | ៣៦២ | ៣៨២ | ៧៤៤ |
| ភូមិព្រាំង ឃុំជងពែង | ១១២ | ៤៨២ | ៤៩១ | ៩៧៣ |

### ៣.២ មុខរបរ សមាជិកសហគមន៍

ការប្រកបមុខរបរចិញ្ចឹមជីវិតរបស់សមាជិកសហគមន៍ភូមិព្រាំងមាន៖ ធ្វើស្រែ៣៧% ដំណាំ១៩% ចិញ្ចឹមសត្វ២៤% នេសាទ៩% ពលកម្មចំណាកស្រុក៦% លក់ដូរ៥% នេសាទ៩% (ស្ថិតិទិន្នន័យភូមិឆ្នាំ២០២៣)។

**ដ្យាក្រាមទី១ បង្ហាញពីមុខរបរ ភូមិព្រាំង ឃុំជងពែង ស្រុកស្រែអំបិល ខេត្តកោះកុង**



ការប្រកបមុខរបរចិញ្ចឹមជីវិតរបស់សមាជិកសហគមន៍ភូមិចំការក្រោម មាន៖ ធ្វើស្រែ៥៧% ដំណាំ៩% ចិញ្ចឹមសត្វ១៦% នេសាទ៦% ពលកម្មចំណាកស្រុក៩% លក់ដូរ៣% នេសាទ៦% ( ស្ថិតិទិន្នន័យភូមិឆ្នាំ២០២៣ )។

**ដ្យាក្រាមទី២ បង្ហាញពីមុខរបរ ភូមិចំការក្រោម ឃុំស្រែអំបិល ស្រុកស្រែអំបិល ខេត្តកោះកុង**




### ៣.៣.សមិទ្ធិផលសំខាន់ៗដែលសហគមន៍សម្រេចបានកន្លងមក

សហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោម បានអនុវត្តតួនាទីក្នុងគ្រប់គ្រង និងការអភិវឌ្ឍន៍សហគមន៍ដោយការគាំទ្រពីអង្គការដៃគូទទួលបាននូវលទ្ធផលសំខាន់ៗមានដូចជា៖

- ការល្បាតទប់ស្កាត់បទល្មើសក្នុងដែនសហគមន៍
- សាងសងស្លាក់ការសហគមន៍បាន១ខ្នង ទំហំ៥ម គុណ ៦ម
- ទទួលអំណោយពីអង្គការមេគគក្រោមម្ចាស់ជំនួយWWFម៉ាស៊ីន១គ្រឿងនិងសម្បកទូកពីសប្បុរសជន ០១ គ្រឿង
- សម្ភារៈមាន ដូចជាឯកសណ្ឋាន វិទ្យុទាក់ អាវពោង និង GPS
- ចាក់ដីបំពេញស្នាក់សហគមន៍ចំនួន២០ឡាន
- សិក្សាអំពីព្រំប្រទល់សហគមន៍បានចំនួន១ដង
- ដាំស្តារព្រៃសហគមន៍ (ដើមលុយ) ចំនួន៣៥០០ដើម។

### ៣.៤.បញ្ហាប្រឈមកំពងជួបប្រទះ

សហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោម បច្ចុប្បន្នកំពុងជួបប្រទះនូវបញ្ហាប្រឈមដែលត្រូវដោះស្រាយមួយចំនួនដូចជា ៖

- ការដកហូតឈើយកមកប្រើប្រាស់ការប្រមូលអនុផលព្រៃសហគមន៍ មិនទាន់ធ្វើការកត់ត្រាបានច្បាស់លាស់នៅឡើយ

- ការចូលលួចកាប់ឈើពីសំណាក់អ្នកខាងក្រៅ
- គណៈកម្មការគ្រប់គ្រងសហគមន៍មានសមត្ថភាពយល់ដឹងនិងការចូលរួមនៅមានកម្រិត
- មិនទាន់បានបោះបង្គោលព្រំប្រទល់ដីពសហគមន៍គ្រប់ចំនួននៅឡើយ
- ទឹកប្រៃហូរចូលដីស្រែប្រជាពលរដ្ឋធ្វើឱ្យការប្រកបមុខរបរធ្វើស្រែមិនសូវបានផល
- សហគមន៍ខ្វះធនធានមនុស្សនិងថវិកាសម្រាប់អភិវឌ្ឍន៍សហគមន៍។

## ៤. ស្ថានភាពធនធានព្រៃសហគមន៍

### ៤.១ ស្ថានភាពធនធានព្រៃសហគមន៍

សហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោម បានប្រកាសទទួលស្គាល់ដោយក្រសួងបរិស្ថានតាមប្រកាសលេខៈ០០៨ប្រក.បស្ថមានផ្ទៃដីព្រៃសរុប ៨៥៩ហិចតា។

ផែនការគ្រប់គ្រងរបស់សហគមន៍ព្រាំងចំការក្រោម ដែលបានរៀបចំលើកទី១(២០២៤-២០២៨) សហគមន៍បានធ្វើសារពើភ័ណ្ឌព្រៃឈើក្នុងតំបន់បែកចែកទុកសម្រាប់ដកហូតយកមកប្រើប្រាស់ ដែលមានផ្ទៃដីទំហំ១៦២.៤០ហិកតា។

ផ្ទៃដីសហគមន៍បានធ្វើការបែងចែកផ្ទៃដីរបស់សហគមន៍ដែលមានទំហំសរុប៨៥៩ហ.ត ជាបួនតំបន់សម្រាប់ធ្វើការគ្រប់គ្រប់រួមមាន តំបន់ប្រើប្រាស់ តំបន់ដាំស្តារឡើងវិញ តំបន់ទេសចរណ៍ធម្មជាតិ និងតំបន់អភិរក្ស។

ព្រៃសហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោមជាប្រភេទព្រៃលិចទឹក ពាក់កណ្តាលស្រោងដុះជាប់មាត់សមុទ្រនិងដៃព្រែកទឹកប្រៃ ។ ស្ថានភាពធនធានព្រៃសហគមន៍បច្ចុប្បន្ននេះមានលក្ខណៈដុះលូតលាស់ល្អប្រសើរមានប្រភេទឈើសំខាន់ៗដូចជា ស្មាច់ ក្រញ៉ូង កោងកាង តាបុនហើយមានការកើនឡើងសត្វស្លាប ឃ្មុំព្រៃ ត្រី ក្តាម បង្គារ ងាវកក់ ដែលជាតម្រូវការក្នុងកាទ្រទ្រង់ជីវភាពរបស់ប្រជាសហគមន៍ ។

### ៤.២ ទីតាំង និងទំហំព្រៃសហគមន៍

ការធ្វើផែនការគ្រប់គ្រងលើទី១ (២០២៥-២០២៩) របស់សហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោមលើផ្ទៃដីចំនួន៨៥៩ហិចតា ដែលក្រសួងបរិស្ថានបានប្រកាសទទួលស្គាល់ ដែលទីតាំងព្រំប្រទល់ និងនិយាមកាចំណុចសំខាន់ៗ ដូចខាងក្រោមៈ

- ខាងជើងជាប់ដីស្រែប្រជាពលរដ្ឋ ភូមិព្រាំង
- ខាងត្បូងជាប់ដីស្រែប្រជាពលរដ្ឋភូមិចំការក្រោម និងដីព្រៃតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង
- ខាងកើតជាប់ដីស្រែប្រជាពលរដ្ឋភូមិដងពែង និងភូមិចំការក្រោម
- ខាងលិចជាប់ព្រែកក្រូច ភូមិព្រាំង និងភូមិចំការក្រោម ហើយមានចំណុចនិយាមកាសំខាន់ៗដូចតារាងខាងក្រោម ៖

| ចំណុច | អាប់ស៊ីស X | អ័រដោនេ Y | ចំណុច | អាប់ស៊ីស X | អ័រដោនេ Y |
|---|---|---|---|---|---|
| A | ៣៥៥៩៧៧ | ១២៣១៩៥៨ | L | ៣៥៦៤៤៩ | ១២២៥៩២៦ |
| B | ៣៥ ៧៥៩៤ | ១២៣១៧៩៤ | M | ៣៥៥៧៨៩ | ១២២៧៩៤២ |
| C | ៣៥ ៨០៨០ | ១២៣០៩១០ | N | ៣៥៧៥៣២ | ១២២៧១៨០ |
| D | ៣៥៨២២៥ | ១២៣១០៥៤ | O | ៣៥៧៧៤៩ | ១២២៧៣៨៩ |

| | | | | | |
|---|---|---|---|---|---|
| E | ៣៥ ៧៩០២ | ១២៣២០៥៤ | P | ៣៥៧៩៩៥ | ១២២៧៧៥៧ |
| F | ៣៥ ៦៥០១ | ១២៣២៥៤៤ | Q | ៣៥៨៨០២ | ១២២៨៣៣៦ |
| G | ៣៥ ៦៦២៩ | ១២២៩២១៥ | R | ៣៥៨៨០២ | ១២២៩០៩៥ |
| H | ៣៥ ៦៤៦៣ | ១២២៨១៨៤ | S | ៣៥៩២០៧ | ១២២៩៦១០ |
| I | ៣៥ ៥២៦៣ | ១២២៨០៥៣ | T | ៣៥៨៥៥៣ | ១២២៩៦៨៦ |
| J | ៣៥ ៤០៥៧ | ១២២៧៦៦៩ | U | ៣៥៨២៩២ | ១២២៩៤៩២ |
| K | ៣៥ ៦០១១ | ១២២៦២២៦ | V | ៣៥៧៨៣៣ | ១២២៩០៨១ |

### ៤.៣ វិធីសាស្ត្រ និងលទ្ធផលនៃការធ្វើសារពើភ័ណ្ឌព្រៃសហគមន៍

ការតាំងឡូត៍សហគមន៍បានចុះធ្វើសារពើភ័ណ្ឌព្រៃជាឡូត៍គំរូ ដោយលក្ខណៈចៃដន្យដែលមានឡូត៍រាយប៉ាយក្នុងព្រៃសហគមន៍ដែលបានកំណត់បែងចែកជាតំបន់សម្រាប់ប្រើប្រាស់ ហើយទំហំឡូត៍ដែលបានអនុវត្តរួមមាន ៖

-០ម x២០ម រាស់ដើមឈើដែលមានអង្កត់ផ្ចិតចាប់ពី១០សមឡើងទៅ

-១០មx១០ម រាស់ដើមឈើដែលមានអង្កត់ផ្ចិតចន្លោះពី ៥-១០សម

-៥មx៥ម រាប់កូនដំណុះដែលមានអង្កត់ផ្ចិតតូចជាង ៥សម ។

**តារាងលទ្ធផលសារពើភ័ណ្ឌធនធានព្រៃឈើ**

| ការបែងចែកតំបន់ | ទំហំផ្ទៃដី | អង្កត់ផ្ចិត | | |
|---|---|---|---|---|
| | | Dពី<៥ស.ម | Dពី៥-១០ស.ម | ≥ ១០សម |
| | | ដើម | ដើម | ដើម |
| តំបន់ប្រើប្រាស់ | 162.40 | 2,997 | 10,486 | 1,938 |
| តំបន់ដាំស្តារ(៥ទីតាំង) | 189.70 | មិនបានធ្វើសារពើភ័ណ្ឌ | | |
| តំបន់ទេសចរណ៍ធម្មជាតិ | 275.90 | | | |
| តំបន់អភិរក្ស | 249 | | | |
| សរុបផ្ទៃដី | 859 | | | |

### ៤.៤ ស្ថានភាពនៃការប្រើប្រាស់ផល-អនុផលព្រៃឈើ

ផ្អែកតាមលទ្ធផលនៃការសិក្សាតាមរយៈការសម្ភាសន៍បានបង្ហាញឱ្យឃើញថាតម្រូវការប្រើប្រាស់ធនធានព្រៃឈើក្នុងសហគមន៍មានតម្រូវការប្រើប្រាស់ផ្សេងៗគ្នាទៅតាមតម្រូវការនិងមុខរបរនៃការចិញ្ចឹមជីវិត ។

បច្ចុប្បន្ននៅក្នុងសហគមន៍មានសមាជិកប្រមាណ៦០%នៃចំនួនគ្រួសារសរុប មានលំនៅដ្ឋានសមរម្យពេលគឺ ផ្ទះដែលមានការសាងសងពីឈើអារ សង់ពីឥដ្ឋ ហើយក៍នៅមានគ្រួសារជាសមាជិកប្រមាណ៤០%ទៀតដែលត្រូវការឈើសម្រាប់សាងសង់លំនៅដ្ឋាន ក្នុងពេលខាងមុខ។

ក្រៅពីការប្រើប្រាស់ឈើសម្រាប់សាងសង់សំណង់ផ្សេងៗ សមាជិកសហគមន៍បានប្រើប្រាស់ផល អនុផល ព្រៃឈើ ជីវចម្រុះក្នុងព្រៃសហគមន៍ដូចជាៈ បន្លែព្រៃ និងរុក្ខជាតិឱសថ ផ្សិតស្នាច់ ទឹកឃ្មុំ ងាវកក់ ចាក់ច្រែង ក្តាមជ័រ ក្តាមថ្ម ក្តាមសេះ បង្គារ ត្រី ។ល។

## ៥. យុទ្ធសាស្ត្រនៃការគ្រប់គ្រង

### ៥.១ រចនាសម្ព័ន្ធគ្រប់គ្រង

សហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោម បានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងមានពីរថ្នាក់គឺថ្នាក់គណៈកម្មការ អមដោយទីប្រឹក្សា និងអ្នកគាំទ្រ និងថ្នាក់អនុគណៈកម្មការតាមភូមិ ។

**រចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ «ព្រាំងចំការក្រោម»**




### ៥.២ ការបែងចែកតំបន់គ្រប់គ្រង

ផែនការគ្រប់គ្រងលើកទី១របស់សហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោម បានធ្វើការបែងចែកជាបួនតំបន់រួមមានៈ តំបន់ប្រើប្រាស់ តំបន់ដាំស្តារឡើងវិញ តំបន់ទេសចរណ៍ធម្មជាតិ និងតំបន់អភិរក្ស ។

#### ៥.២.១តំបន់ប្រើប្រាស់

តំបន់ប្រើប្រាស់ដែលមានទំហំផ្ទៃដី១៦២.៤០ហិកតា សមាជិកសហគមន៍អាចដកហូតប្រើប្រាស់លក្ខណៈប្រពៃណីនិងសម្រាប់ធ្វើការសាងសង់ជួសជុលលំនៅដ្ឋាន ធ្វើរបង ទ្រុងមាន់ ទ្រុងគោ ក្របី របស់សមាជិកសហគមន៍ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសហគមន៍ និងការប្រមូលផលអនុផលធនធានធម្មជាតិសម្រាប់ជីវភាពប្រចាំថ្ងៃ ។

#### ៥.២.២ ដីដាំស្តារឡើងវិញ

តំបន់ដាំស្តារព្រៃឈើមានទំហំផ្ទៃដី១៨៩.៧០ហិកតា ជាតំបន់ព្រៃឈើធ្លាប់ទទួលរងនូវការកាប់ចំការពនេចរ កាប់ប្រើប្រាស់មិនមានការគ្រប់គ្រង ជាដីព្រៃរិចរិលតាមកន្លែងខ្លះនៅឡើយ។

#### ៥.២.៣ តំបន់អភិរក្ស

តំបន់អភិរក្សមានផ្ទៃដី**២៤៩ ហិកតា** តំបន់ដែលមានដើមឈើធំខ្ពស់ៗច្រើនបើប្រៀបធៀបទៅនឹងបីតំបន់ផ្សេងទៀត និងមានផ្ទៃដីធំជាងគេ ។ ហើយការកំណត់តំបន់អភិរក្សក្នុងគោលបំណងធ្វើការគ្រប់គ្រងតំបន់អភិរក្សដើម្បីជានានិរន្តរភាពធនធានធម្មជាតិក្នុងសហគមន៍ ជាពិសេសតំបន់នេះជាទីជម្រកដ៏សំខាន់សម្រាប់ការរស់នៅរបស់សត្វព្រៃ និងជីវចម្រុះគ្រប់ប្រភេទផងដែរ ។

#### ៥. ២.៤ តំបន់ទេសចរណ៍ធម្មជាតិ

តំបន់ទេចរណ៍មានផ្ទៃដី២៥៧.៩០ហិកតា ស្ថានភាពព្រៃតំបន់នេះដុះតាមទំនាប់មាត់អូរ និងតាមមាត់ព្រែកភាគច្រើនជាប្រភេទដើមស្នាច់ ដើមកោងកាង ដើមក្រញឹប ដើមលុយ ដើមចាកនិងស្មៅ។

បំណងនៃការគ្រប់គ្រងតំបន់នេះគឺថែរក្សាទីជំរាល និងទីជម្រកសម្រាប់ពពួកសត្វព្រៃគ្រប់ប្រ

ភេទនិងសម្រាប់សហគមន៍រៀបចំជាតំបន់ទេសចរណ៍ធម្មជាតិនៅពេលខាងមុខដើម្បីលើកស្ទួយជីវភាពសមាជិកសហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោម បានប្រសើរឡើង ។

## ៥.៣ គោលការណ៍ប្រើប្រាស់ផល អនុផលព្រៃឈើ

ការកំណត់លក្ខខណ្ឌប្រើប្រាស់ផលអនុផលព្រៃឈើនៅក្នុងសហគមន៍ធ្វើឡើង ដោយផ្អែកទៅលើធនធានដែលមាននៅក្នុងព្រៃសហគមន៍និង តម្រូវការប្រើប្រាស់ចាំបាច់របស់សមាជិកសហគមន៍ ។ ម្យ៉ាងវិញទៀតគោលការណ៍នេះត្រូវអនុវត្តស្របតាមទិដ្ឋភាពច្បាប់ស្តីពី ក្រមបរិស្ថាននិងធនធម្មជាតិ និងលក្ខន្តិកៈរបស់សហគមន៍ផងដែរ។ ក្រមបរិស្ថាន និងធនធានធម្មជាតិ( ជំពូកទី៦ **មាត្រា៣៦៩** ស្តីពីសិទ្ធិប្រើប្រាស់ធនធានធម្មជាតិ និង**មាត្រា៣៧០** ស្តីពីការប្រើប្រាស់ធនធានធម្មជាតិ ) សហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោម លក្ខខណ្ឌនៃប្រើប្រាស់ផល អនុផលព្រៃឈើ មានដូចខាងក្រោមនេះ៖

### ៥.៣.១ ការប្រើប្រាស់ឈើសំណង់

សមាជិកសហគមន៍ដែលត្រូវការឈើសង់លំនៅដ្ឋាន ត្រូវធ្វើសំណើរជាលាយល័ក្សអក្សរទៅគណៈកម្មការគ្រប់គ្រងសហគមន៍ និងជម្រាបជូននាយតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង។

សមាជិកសហគមន៍អាចស្នើសុំឈើយកមកប្រើប្រាស់ជាលក្ខណៈគ្រួសារបានតែមិនអនុញ្ញាតយកទៅធ្វើអាជីវកម្មឡើយ ។

ការសាងសង់លំនៅដ្ឋានដែលប្រើប្រាស់កូនឈើមូលសហគមន៍តំបន់ការពារធម្មជាតិអនុញ្ញាត្តបានជូនដល់សមាជិកចំនួន៤គ្រួសារ ក្នុងមួយឆ្នាំ។

ការសម្រេចផ្តល់ឈើជូនគ្រួសារជាសមាជិកណាមួយ ត្រូវធ្វើឡើងតាមរយៈកិច្ចប្រជុំប្រចាំខែរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ ។

ក្នុងករណីសហគមន៍ត្រូវការឈើប្រើប្រាស់ជាលក្ខណៈរួម(វត្តសាលារៀន ស្ពាន...)គណៈកម្មគ្រប់គ្រងសហគមន៍ត្រូវធ្វើការប្រជុំសុំការឯកភាពពីសមាជិកសហគមន៍ចំនួន២ភាគ៣ និងសុំការឯកភាពពីនាយកតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង តាមរយៈក្រុមប្រឹក្សាឃុំ ។

### ៥.៣.២ កូនឈើបង្គោលរបង ឈើចំរឹង ឬជន្ទល

សមាជិកសហគមន៍អាចស្នើសុំកាប់ បង្គោលរបងប្រើប្រាស់ជាលក្ខណៈគ្រួសារ ចំនួន១០០បង្គោលក្នុងមួយគ្រួសារ ហើយក្នុងរយៈពេល**៣ឆ្នាំ** ទើបអនុញ្ញាត្តឱ្យសុំម្តងទៀត ។

សមាជិកសហគមន៍អាចស្នើសុំកាប់កូនឈើជាបង្គោលសម្រាប់ធ្វើរោងគោទ្រង់ ជ្រូក ចំនួន**២០ដើម**ក្នុងមួយគ្រួសារហើយក្នុងមួយភូមិអាចផ្តល់ជូនត្រឹម**៥គ្រួសារ** ក្នុងមួយឆ្នាំ ។

សមាជិកសហគមន៍អាចស្នើសុំកាប់កូនឈើសម្រាប់ធ្វើទ្រុងមាន់ ទ្រុងទា ទៅតាមតម្រូវការប្រើប្រាស់ជាក់ស្តែង ។

ប្រជាជនដែលមិនមែនជាសមាជិកសហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោមអនុញ្ញាតឲ្យកាប់ឈើយកទៅប្រើប្រាស់ត្រូវមានការឯកភាពពីគណៈកម្មការគ្រប់គ្រងសហគមន៍ជាមុននិងមានការឯកភាពពីក្រុមប្រឹក្សាឃុំ។

### ៥.៣.៣ ការប្រើប្រាស់អុស

ការប្រើប្រាស់អុសមិនអនុញ្ញាត្តឱ្យកាប់កូនឈើរស់គ្រប់ប្រភេទ និងមិនអនុញ្ញាតប្រមូលអុសលក់ធ្វើអាជីវកម្មឡើយ ។

សមាជិកសហគមន៍អាចប្រមូលអុសក្នុងព្រៃសហគមន៍ (ឈើងាប់ដោយធម្មជាតិ)ប្រើប្រាស់ជាលក្ខណៈគ្រួសារ និងធ្វើការកត់ត្រារាយការណ៍ជូនគណៈកម្មការសហគមន៍ដើម្បីសរុបប្រចាំឆ្នាំ ។

ប្រជាជនដែលមិនមែនជាសមាជិកសហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោមអនុញ្ញាតឱ្យប្រមូលអុសក្នុងតំបន់ព្រៃសហគមន៍ត្រូវមានការឯកភាពពីគណៈកម្មការគ្រប់គ្រងសហគមន៍ ។

### ៥.៤. គោលការណ៍បែងចែកផលប្រយោជន៍

ការបែងចែកផលប្រយោជន៍ជាកត្តាសំខាន់មួយនៅក្នុងការគ្រប់គ្រងសហគមន៍ ប្រសិនបើការបែងចែកផលប្រយោជន៍មិនប្រកបដោយសមធម៌ គ្មានតម្លាភាពនោះវាជាមូលហេតុធ្វើឱ្យមានទំនាស់កើតឡើងឬអាចឈានទៅដល់ការបរាជ័យនៅក្នុងការគ្រប់គ្រងរបស់សហគមន៍ទាំងមូល។

សម្រាប់ការអនុវត្តផែនការគ្រប់គ្រងលើកទី១ (២០២៥២០២៩) សហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោម បានកំណត់នូវគោលការណ៍បែងចែកផលប្រយោជន៍ដូចខាងក្រោម៖

គ្រួសារទីទាល់ក្រ និងងាយរងគ្រោះដែលជាសមាជិកសហគមន៍មានអាទិភាពក្នុងការទទួលបានឈើសម្រាប់ការជួសជុល និងសាងសង់លំនៅដ្ឋានរួមទាំងតម្រូវការប្រើប្រាស់ផ្សេងៗ ។

ថវិកាសហគមន៍ដែលទទួលបានពីគ្រប់ប្រភពទាំងអស់ មិនអនុញ្ញាតឱ្យធ្វើការប្រើប្រាស់ជាលក្ខណៈបុគ្គលឡើយ ត្រូវអនុវត្តតាមខ្លឹមសារដែលចែងក្នុងលក្ខន្តិកៈរបស់សហគនម៍ ហើយរាល់ការចំណាយត្រូវមានការប្រជុំឯកភាពពីគណៈកម្មការសហគមន៍ និងមានការកត់ត្រាច្បាស់លាស់ដោយហិរញ្ញិកសហគមន៍ហើយមានការដឹងលឺពីក្រុមប្រឹក្សាឃុំ ។

ថវិកាចំណូលរបស់សហគមន៍ដែលបានមកពីគ្រប់ផ្នែកទាំងអស់ ត្រូវធ្វើការបែងចែកទៅលើការងារអភិរក្ស**៣០%** ការងារអភិវឌ្ឍន៍**៣០%** ការងារជួយសង្គ្រោះដល់សហគមន៍**១៥%** និងសម្រាប់តម្កល់ទុកក្នុងមូលនិធិសហគមន៍ចំនួន**២៥%**។

### ៥.៥. ការអភិវឌ្ឍអាជីវកម្មខ្នាតតូចក្នុងសហគមន៍

ការរៀបចំផែនការផែនការគ្រប់គ្រងលើកទី១(២០២៥-២០២៩) សហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោមបានកំណត់ផែនការអាជីវកម្មខ្នាតតូចក្នុងសហគមន៍ ដើម្បីបង្កើនការងារ និងប្រាក់ចំណូលលើកកម្ពស់ជីវភាពសមាជិកសហគមន៍តាមរយៈការរៀបចំផ្តល់សេវាកម្មទេសចរណ៍ធម្មជាតិ ។

ដើម្បីសម្រេចបានលើការងារនេះសហគមន៍កំណត់នូវលក្ខខណ្ឌការងារដូចខាងក្រោម៖

- គណៈកម្មការគ្រប់គ្រងសហគមន៍ត្រូវជួបប្រជុំពិភាក្សាជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ និងទីប្រឹក្សាស្វែងរក អង្គការដៃគូ សប្បុរសជន ដើម្បីជួយសម្របសម្រួលក្នុងដំណើរការនេះ ។
- គណៈកម្មការសហគមន៍ត្រូវរៀបចំក្រុមការងារផ្តល់សេវាទេសចរណ៍ធម្មជាតិ ។
- គណៈកម្មការសហគមន៍ត្រូវសិក្សាទីតាំង និងរៀបចំកន្លែងដែលមានភាពទាក់ទាញសម្រាប់អ្នកទេសចរណ៍មកកំសាន្ត ។
- ដំណើរការរៀបចំការផ្តល់សេវាទេសចរណ៍ធម្មជាតិត្រូវធ្វើជាជំហានៗតាមលទ្ធភាព និងធនធានជាក់ស្តែងស្របតាមកំណើននៃចំនួនភ្ញៀវទេសចរ ។

គណៈកម្មការគ្រប់គ្រងសហគមន៍ត្រូវរៀបចំកន្លែងសម្រាប់ភ្ញៀវសម្រាកកំសាន្ត ចំទីចំណតរថយន្ត និងទីតាំងទុកដាក់សម្រាមឱ្យបានត្រឹមត្រូវ ។

គណៈកម្មការគ្រប់គ្រងសហគមន៍ត្រូវធ្វើការប្រជុំត្រួតពិនិត្យ និងវាយតម្លៃប្រចាំខែ ដើម្បីធ្វើ

ការកែលំអរសេវាកម្មទេសចរណ៍តាមស្ថានភាពជាក់ស្តែង ។

## ៦. ផែនការអភិវឌ្ឍន៍សម្រាប់៥ឆ្នាំ និងផែនការអនុវត្តន៍ប្រចាំឆ្នាំនីមួយៗ

ផ្អែកតាមទស្សនៈវិស័យដែលបានកំណត់ឡើងក្នុងការរៀបចំផែនការគ្រប់គ្រង លើកទីមួយ សហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោម បានកំណត់នូវផែនការសកម្មភាពជាអាទិភាពមួយចំនួន សម្រាប់សហគមន៍អនុវត្តមានក្នុងតារាងខាងក្រោម៖

**តារាងផែនការសកម្មភាពរយៈពេល៥ឆ្នាំ** (២០២៥-២០២៩)

| ល.រ | សកម្មភាព | ឆ្នាំ | | | | |
|---|---|---|---|---|---|---|
| | | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ |
| ១ | រៀបចំបង្កើតតំបន់ទេសចរណ៍ធម្មជាតិ | | | | | |
| ២ | បណ្តុះកូនឈើព្រៃ និងកូនឈើហូបផ្លែ | | | | | |
| ៣ | ដាំស្តារព្រៃឈើឡើងវិញ | | | | | |
| ៤ | រៀបចំក្រុមកែច្នៃផលជលផលសមុទ្រ | | | | | |
| ៥ | រៀបចំក្រុមអភិរក្សក្តាម ងាវភក់ និងសត្វឃ្មុំ | | | | | |
| ៦ | រៀបចំសាងសង់ទំនប់ទឹកប្រៃ | | | | | |
| ៧ | រៀបចំសាងសង់អណ្តូងទឹក(លូ) | | | | | |
| ៨ | រៀបចំក្រុមកសិកម្មចម្រុះជាលក្ខណៈគ្រួសារ | | | | | |
| ៩ | សកម្មភាពល្បាតព្រៃសហគមន៍ | | | | | |
| ១០ | រៀបចំធ្វើផ្លូវចូលដីសហគមន៍ | | | | | |
| ១១ | បោះឆ្នោតជ្រើសរើសគណៈកម្មការអាណត្តថ្មី | | | | | |
| ១២ | កិច្ចប្រជុំប្រចាំឆ្នាំក្នុងសហគមន៍ | | | | | |
| ១៣ | បង្គោលព្រំនិងផ្លាកសំគាល់សហគមន៍ | | | | | |
| ១៤ | រៀបចំទិវាអនាម័យបរិស្ថាន | | | | | |
| ១៥ | ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | | | | | |
| ១៦ | រៀបចំកែលម្អស្នាក់ការសហគមន៍ | | | | | |
| ១៩ | ពង្រឹងសមត្ថភាពនិងបណ្តុះបណ្តាល គណៈកម្មការ | | | | | |
| ២០ | រៀបចំទីលានចាក់សំរាម | | | | | |
| ២១ | បង្កើតក្រុមសន្សំប្រាក់ | | | | | |
| ២២ | ធ្វើផែនការរយៈពេល៥ឆ្នាំ | | | | | |

## ១. តារាងផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំទី១ (២០២៥)

| ល.រ | សកម្មភាព | អ្នកចូលរួម | ពេលវេលាអនុវត្តក្នុងខែ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ១ | ប្រជុំប្រចាំខែ ប្រជុំឆមាស និងឆ្នាំ | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សាសមាជិក | | | | | | | | | | | | |
| ២ | ប្រជុំឆ្លុះបញ្ចាំងប្រចាំឆមាស | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សាសមាជិក | | | | | | | | | | | | |
| ៣ | ល្បាតព្រៃសហគមន៍ | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |
| ៤ | រៀបចំក្រុមដាំបន្លែនិងចិញ្ចឹមសត្វ | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |
| ៥ | បណ្តុះបណ្តាលពីការធ្វើកសិកម្មចម្រុះ | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា សមាជិក | | | | | | | | | | | | |
| ៦ | រៀបចំទិវាអនាម័យបរិស្ថាន | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា សមាជិក | | | | | | | | | | | | |
| ៧ | រៀបចំធ្វើរចនាសម្ព័ន្ធសហគមន៍ | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |
| ៨ | ដាំស្តារព្រៃសហគមន៍ | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា សមាជិក | | | | | | | | | | | | |
| ៩ | កំណត់តំបន់ទេសចរណ៍ធម្មជាតិ | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |
| ១០ | ធ្វើបច្ចុប្បន្នភាពសមាជិក និងប្រមូលវិភាគទាន | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា | | | | | | | | | | | | |
| ១១ | រៀបចំថ្នាលបណ្តុះកូនឈើ | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |
| ១២ | គៀងគរថវិកា | គណៈកម្មការ | | | | | | | | | | | | |
| ១៣ | បោះបង្គោលព្រំបន្ថែមនិងដាក់ស្លាកសញ្ញាហាមឃាត់ | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |

## ២. តារាងផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំទី២ (២០២៦)

| ល.រ | សកម្មភាព | អ្នកចូលរួម | ពេលវេលាអនុវត្តក្នុងខែ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ១ | ប្រជុំប្រចាំខែរៀងរាល់ចុងខែ | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា | | | | | | | | | | | | |
| ២ | ប្រជុំឆមាស និងឆ្នាំ | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា សមាជិក | | | | | | | | | | | | |
| ៣ | ការចុះល្បាតព្រៃ | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |
| ៤ | កំណត់ទីតាំងអភិរក្សក្ដាមខ្យង ឃុំ | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |
| ៥ | សាងសង់បន្ទប់ទឹកសហគមន៍ | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា សមាជិក | | | | | | | | | | | | |
| ៦ | រៀបចំទីលានចាក់សម្រាមនិងធុងអនាម័យ | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា សមាជិក | | | | | | | | | | | | |
| ៧ | រៀបចំក្រុមសេវកម្មសម្រាប់ភ្ញៀវទេសចរណ៍ | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា សមាជិក | | | | | | | | | | | | |
| ៨ | ទិវាបរិស្ថាននិងអនាម័យ | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |
| ៩ | ដាំស្ដារព្រៃសហគមន៍ | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា សមាជិក | | | | | | | | | | | | |
| ១០ | រៀបចំក្រុមស្ត្រីកែច្នៃផលសមុទ្រ | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា | | | | | | | | | | | | |
| ១១ | រៀបចំចងក្រងក្រុមអភិរក្ស និងចិញ្ចឹមឃុំ | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |
| ១២ | កែលំអស្នាក់ការសហគមន៍ | គណៈកម្មការ ក្រុមអ្នកផ្ដល់សេវាអេកូទេសចរណ៍ | | | | | | | | | | | | |

## ៣. តារាងផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំទី៣ (២០២៧)

| ល.រ | សកម្មភាព | អ្នកចូលរួម | ពេលវេលាអនុវត្តមានក្នុងមួយខែ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ | ៦ | | ៨ | ៩ | ១០ | ១១ | ១២ |
| ១ | ប្រជុំប្រចាំខែរៀងរាល់ចុងខែ | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា | | | | | | | | | | | | |
| ២ | ប្រជុំឆមាស និងឆ្នាំ | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា សមាជិក | | | | | | | | | | | | |
| ៣ | ការចុះល្បាតព្រៃ | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |
| ៤ | ស្តារប្រឡាយនិងលើកទំនប់ចូលដីសហគមន៍ | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |
| ៥ | រៀបចំរោងលំហែកាយនិងមធ្យោបាយដឹកជញ្ជូន | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា សមាជិក | | | | | | | | | | | | |
| ៦ | រៀបចំចំណត់ម៉ូតូនិងរថយន្ត | គណៈកម្មការ | | | | | | | | | | | | |
| ៧ | រៀបចំរោងអាហារសម្រាប់ភ្ញៀវ | គណៈកម្មការ ប្រធានក្រុម | | | | | | | | | | | | |
| ៨ | រៀបចំអនាម័យបរិស្ថាន | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |
| ៩ | ទស្សនៈកិច្ចសិក្សា/សិក្ខាសាលា | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា សមាជិក | | | | | | | | | | | | |
| ១០ | បណ្ដុះកូនឈើ | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |
| ១១ | ទិញសម្ភារៈ | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា | | | | | | | | | | | | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ការិយាល័យ | | | | | | | | | | | | | |
| ១២ | ដាំស្តារព្រៃសហគមន៍ | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |
| ១៣ | បណ្តុះបណ្តាលពីភាពជាអ្នកដឹកនាំ | គណៈកម្មការ<br>ក្រុមអ្នកផ្តល់សេវាអេកូទេសចរណ៍ | | | | | | | | | | | | |
| ១៤ | តាមដាននិងពិនិត្យក្រុមកែច្នៃផលសមុទ្រ | | | | | | | | | | | | | |

## ៤. តារាងផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំទី៤ (២០២៨)

| ល.រ | សកម្មភាព | អ្នកចូលរួម | ពេលវេលាអនុវត្តក្នុងខែ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | | ៩ | ១០ | ១១ | ១២ |
| ១ | ប្រជុំប្រចាំខែរៀងរាល់ចុងខែ | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា | | | | | | | | | | | | |
| ២ | ប្រជុំធមាស និងឆ្នាំ | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា សមាជិក | | | | | | | | | | | | |
| ៣ | ការចុះល្បាតព្រៃ | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |
| ៤ | ស្តារប្រឡាយនិងជុសជុលឡើងវិញ | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |
| ៦ | រៀបចំក្រុមសេវាកម្មកញ្ចុះ | គណៈកម្មការ<br>ក្រុមអ្នកផ្តល់សេវាអេកូទេសចរណ៍ | | | | | | | | | | | | |
| ៧ | រៀបចំក្រុមសេវាកម្មចុងភៅ | គណៈកម្មការ<br>ក្រុមអ្នកផ្តល់សេវាអេកូទេសចរណ៍ | | | | | | | | | | | | |
| ៨ | រៀបចំក្រុមសេវាកម្មនាំភ្ញៀវ | គណៈកម្មការ<br>ក្រុមអ្នកផ្តល់សេវាអេកូទេសចរណ៍ | | | | | | | | | | | | |
| ៩ | រៀបចំអនាម័យបរិស្ថាន | គណៈកម្មការ ក្រុមសេវាអេកូទេសចរណ៍ | | | | | | | | | | | | |
| ១០ | ទស្សនៈកិច្ចសិក្សា/សិក្ខាសាលា | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១១ | បណ្តុះកូនឈើ | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា | | | | | | | | | | | | |
| ១២ | ទិញសម្ភារៈការិយាល័យ | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |
| ១៣ | បណ្តុះបណ្តាលស្តីពីការធ្វើអាជីវកម្មខ្នាតតូច | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |

## ៥. តារាងផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំទី៥ (២០២៩)

| ល.រ | សកម្មភាព | អ្នកចូលរួម | ពេលវេលាអនុវត្តក្នុងខែ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ១ | ប្រជុំប្រចាំខែរៀងរាល់ចុងខែ | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា | | | | | | | | | | | | |
| ២ | ប្រជុំឆមាស និងឆ្នាំ | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា សមាជិក | | | | | | | | | | | | |
| ៣ | ការចុះល្បាតព្រៃ | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |
| ៤ | ស្តារប្រឡាយនិងជុសជុលឡើងវិញ | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |
| ៥ | រៀបចំក្រុមសេវាកម្មកញ្ចុះ | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា សមាជិក | | | | | | | | | | | | |
| ៦ | រៀបចំក្រុមសេវាកម្មចុងភៅ | គណៈកម្មការ ប្រធានក្រុម | | | | | | | | | | | | |
| ៧ | រៀបចំក្រុមសេវាកម្មនាំភ្ញៀវ | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |
| ៨ | រៀបចំអនាម័យបរិស្ថាន | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា សមាជិក | | | | | | | | | | | | |
| ៩ | ទស្សនៈកិច្ចសិក្សា/សិក្ខាសាលា | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |
| ១០ | បណ្តុះកូនឈើ | គណៈកម្មការ ប្រធានក្រុម ទីប្រឹក្សា | | | | | | | | | | | | |
| ១១ | ទិញសម្ភារៈការិយាល័យ | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |
| ១២ | អនុវត្តគោលការណ៍ដកហូតអនុផលព្រៃឈើ | គណៈកម្មការ ប្រធានក្រុម សមាជិក | | | | | | | | | | | | |
| ១៣ | បោះឆ្នោតគណៈកម្មការអាណត្តិថ្មី | | | | | | | | | | | | | |
| ១៤ | រៀបចំធ្វើផែនការគ្រប់គ្រង៥ឆ្នាំបន្ត | គណៈកម្មការមន្ទីរបរិស្ថាន អ្នកពាក់ព័ន្ធ | | | | | | | | | | | | |

## ៧.យន្តការត្រួតពិនិត្យនិងវាយតម្លៃ

ការត្រួតពិនិត្យ និងវាយតម្លៃគឺជាមធ្យោបាយមួយដ៏សំខាន់សម្រាប់ជួយពង្រឹងដល់ដំណើរការអនុវត្តរបស់សហគមន៍ក្នុងដំណើរការគ្រប់គ្រងធនធានធម្មជាតិក៏ដូចជាការងារអភិវឌ្ឍន៍អេកូទេសចរណ៍ ព្រមទាំងជួយឱ្យសម្រេចបាននូវគោលបំណងនិងទស្សនៈវិស័យរបស់សហគមន៍ ។ ដំណើរការត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តផែនការគ្រប់គ្រងនេះសហគមន៍បានកំណត់នូវយន្តការត្រួតពិនិត្យនិងវាយតម្លៃដោយផ្អែកលើគោលការណ៍ទាំងបួននៃការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ប្រកបដោយនិរន្តរភាពដូចមានខ្លឹមសារនៅក្នុងតារាងខាងក្រោម៖

| លក្ខណៈវិនិច្ឆ័យ/លក្ខណៈវិនិច្ឆ័យរង/ សូចនាករ (ពិន្ទុសរុបៈ៣៤៥) | តារាងដាក់ពិន្ទុ | | | | | |
|---|---|---|---|---|---|---|
| | ០ | ១ | ២ | ៣ | ៤ | ៥ |
| ១.សមត្ថភាពដឹកនាំរបស់គណៈកម្មការ(ពិន្ទុ៤០) | | | | | | |
| *១.១.ការចាត់ចែងការងារ(ពិន្ទុ២៥)* | | | | | | |
| បានប្រជុំប្រចាំខែ ប្រចាំត្រីមាសជាមួយៈសមាជិកគណៈកម្មការ ឬសមាជិកសហគមន៍ | | | | | | |
| បានធ្វើរបាយការណ៍ជូនអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធជាប្រចាំ | | | | | | |
| បានទុកដាក់ឯកសារ លិខិតស្នាមសហគមន៍ និងឯកសារពាក់ព័ន្ធត្រឹមត្រូវ | | | | | | |
| បានបែងចែកការទទួលខុសត្រូវរបស់សមាជិកគណៈកម្មការសហគមន៍ | | | | | | |
| មានស្នាក់ការសហគមន៍ | | | | | | |
| *១.២.ការទំនាក់ទំនង និងកិច្ចសហការ(ពិន្ទុ១៥)* | | | | | | |
| បានសហការជាមួយមេភូមិ និងឃុំ | | | | | | |
| បានសហការជាមួយមន្ត្រីឧទ្យានុរក្ស | | | | | | |
| បានសហការជាមួយអង្គការ និងដៃគូពាក់ព័ន្ធ | | | | | | |
| ២.ការគ្រប់គ្រងធនធានធម្មជាតិក្នុងដែនព្រៃសហគមន៍(ពិន្ទុ៧៥) | | | | | | |
| *២.១. ផែនការគ្រប់គ្រង និងសកម្មភាពអនុវត្ត(ពិន្ទុ៣៥)* | | | | | | |
| បានរៀបចំផែនការគ្រប់គ្រងសហគមន៍ | | | | | | |
| បានបោះបង្គោលព្រំសហគមន៍ | | | | | | |
| បានបែងចែកតំបន់គ្រប់គ្រងក្នុងសហគមន៍ | | | | | | |

| លក្ខណៈវិនិច្ឆ័យ/លក្ខណៈវិនិច្ឆ័យរង/ សូចនាករ (ពិន្ទុសរុបៈ៣៤៥) | តារាងដាក់ពិន្ទុ | | | | | |
|---|---|---|---|---|---|---|
| | ០ | ១ | ២ | ៣ | ៤ | ៥ |
| មានផែនការ និងបានដាំស្តារព្រៃឈើក្នុងសហគមន៍ | | | | | | |
| មានផ្ទាំងផែនទីបញ្ជាក់ទីតាំងសហគមន៍ (បោះតាំងនៅច្រកចូល) | | | | | | |
| បានទុកដាក់ឧបករណ៍ និងសម្ភារៈរបស់សហគមន៍ដោយសុវត្ថិភាព | | | | | | |
| បានបោះស្លាកសញ្ញាការពារព្រៃក្នុងដែនសហគមន៍ | | | | | | |
| *២.២.ការទប់ស្កាត់បទល្មើស និងហានិភ័យ(ពិន្ទុ២៥)* | | | | | | |
| បានការចុះល្បាតព្រៃសហគមន៍ | | | | | | |
| បានទប់ស្កាត់ការកាប់រុករានដីព្រៃសហគមន៍ | | | | | | |
| បានទប់ស្កាត់ការលួចកាប់ឈើក្នុងសហគមន៍ | | | | | | |
| បានទុកដាក់ឧបករណ៍ល្មើសខុសច្បាប់ក្នុងសហគមន៍ដោយត្រឹមត្រូវ | | | | | | |
| បានទប់ស្កាត់ ឬ ពន្លត់ភ្លើងឆេះព្រៃ | | | | | | |
| *២.៣.ការចូលរួមរបស់សហគមន៍(ពិន្ទុ១៥)* | | | | | | |
| សមាជិកបានចូលរួមរាល់សកម្មភាពក្នុងសហគមន៍ | | | | | | |
| សមាជិកជាស្ត្រីចូលរួមក្នុងសកម្មភាពសហគមន៍ | | | | | | |
| អាជ្ញាធរភូមិ ឃុំបានចូលរួមក្នុងសកម្មភាពសហគមន៍ | | | | | | |
| ៣.ការដោះស្រាយបញ្ហាប្រឈម(ពិន្ទុ៣៥) | | | | | | |
| *៣.១.យន្តការដោះស្រាយទំនាស់(ពិន្ទុ២០)* | | | | | | |
| បានដោះស្រាយក្នុងជួរគណៈកម្មការសហគមន៍នៅនឹងកន្លែង | | | | | | |
| បានជូនដំណឹង ឬ សុំអន្តរាគមន៍ពីសមត្ថកិច្ចដែន(មន្ត្រីឧទ្យានុរក្ស) | | | | | | |
| បានជូនដំណឹង ឬ សុំអន្តរាគមន៍ពីអាជ្ញាធរដែនដី(ឃុំ ស្រុក) | | | | | | |

| លក្ខណៈវិនិច្ឆ័យ/លក្ខណៈវិនិច្ឆ័យរង/ សូចនាករ (ពិន្ទុសរុបៈ៣៨៥) | តារាងដាក់ពិន្ទុ | | | | | |
|---|---|---|---|---|---|---|
| | ០ | ១ | ២ | ៣ | ៤ | ៥ |
| បានធ្វើកំណត់ហេតុ ឬកិច្ចសន្យាជាមួយជនល្មើស | | | | | | |
| *៣.២.យន្តការដោះស្រាយទៅតុលាការ(ពិន្ទុ១៥)* | | | | | | |
| បានសរសេរពាក្យបណ្ដឹង និងដាក់ពាក្យបណ្ដឹងទៅតុលាការ | | | | | | |
| បានរាយការណ៍ជូនអ្នកពាក់ព័ន្ធអំពីការធ្វើបណ្ដឹង | | | | | | |
| បានចូលរួមបំភ្លឺនៅតុលាការ(ខេត្ត ឧទ្ធរណ៍ កំពូល) | | | | | | |
| ៤.បទដ្ឋានគតិយុត្ត(ពិន្ទុ៤៥) | | | | | | |
| *៤.១.មានបទដ្ឋានគតិយុត្ត(ពិន្ទុ៣០)* | | | | | | |
| មានលិខិតស្នើសុំរៀបចំសហគមន៍ និងបានដាក់មកអង្គភាពទទួលខុសត្រូវ | | | | | | |
| មានរចនាសម្ព័ន្ធដឹកនាំសហគមន៍ | | | | | | |
| មានប្រកាសទទួលស្គាល់ពីក្រសួងបរិស្ថាន | | | | | | |
| មានលក្ខន្តិកៈសហគមន៍ | | | | | | |
| មានផែនការគ្រប់គ្រងសហគមន៍ | | | | | | |
| មានកិច្ចព្រមព្រៀង | | | | | | |
| *៤.២.ការអនុវត្តបទដ្ឋានគតិយុត្ត(ពិន្ទុ ១៥)* | | | | | | |
| បានបែងចែកការងារដឹកនាំ ទៅតាមរចនាសម្ព័ន្ធដឹកនាំដែលមាន | | | | | | |
| បានអនុវត្តន៍តាមលក្ខន្តិកៈសហគមន៍ | | | | | | |
| បានយល់ និងអនុវត្តន៍ការងារសហគមន៍តាមផែនការគ្រប់គ្រង | | | | | | |
| ៥.ការកែលម្អអនាម័យ និងសុខភាព(ពិន្ទុ៤០) | | | | | | |
| *៥ ១.បង្កើនការយល់ដឹងពីសុខភាពអនាម័យ (ពិន្ទុ១៥)* | | | | | | |

| លក្ខណៈវិនិច្ឆ័យ/លក្ខណៈវិនិច្ឆ័យរង/ សូចនាករ (ពិន្ទុសរុបៈ៣៤៥) | តារាងដាក់ពិន្ទុ | | | | | |
|---|---|---|---|---|---|---|
| | ០ | ១ | ២ | ៣ | ៤ | ៥ |
| មានការណែនាំ និងផ្សព្វផ្សាយពីការប្រើប្រាស់ទឹកស្អាត | | | | | | |
| មានការផ្សព្វផ្សាយពីសុខភាព អនាម័យ និងបរិស្ថាន | | | | | | |
| មានស្លាកសញ្ញាណែនាំពីការប្រើប្រាស់បន្ទប់ទឹក រវាងបុរស និង ស្ត្រី | | | | | | |
| *៥.២.ការអនាម័យសុខភាព (ពិន្ទុ២៥)* | | | | | | |
| មានបន្ទប់ទឹកស្អាត | | | | | | |
| មានបន្ទប់ទឹកដាច់ដោយឡែករវាងបុរស និងស្ត្រី | | | | | | |
| មានអ្នកបោសសំអាត | | | | | | |
| មានកន្លែងលៀងដៃមុន និងក្រោយបន្ទប់ទឹកស្អាត | | | | | | |
| មានប្រអប់សង្គ្រោះបឋម | | | | | | |
| ៦.ការគាំពារបរិស្ថាន(ពិន្ទុ៣០) | | | | | | |
| *៦.១.ការអប់រំ ផ្សព្វផ្សាយស្តីពីការគាំពារបរិស្ថាន (ពិន្ទុសរុប១៥)* | | | | | | |
| មានបទបញ្ជានៃនាំពីការទុកដាក់សំរាម | | | | | | |
| មានការណែនាំស្តីពីការដាក់ពិន័យ លើការបោះចោលសំរាមខុសទីតាំង | | | | | | |
| មានការណែនាំពីការប្រើប្រាស់ជីគីមី និងថ្នាំពុល | | | | | | |
| *៦.២.ការទុកដាក់សមណល់រឹងរាវ(ពិន្ទុ១៥)* | | | | | | |
| មានធុងដាក់សំរាម និងធុងញែកសំរាម | | | | | | |
| មានយន្តការដឹកជញ្ជូនសំរាម | | | | | | |
| មានរណ្តៅដាក់សំរាម ដែលធានាបាននូវសុវត្ថិភាព | | | | | | |
| ៧.គណនេយ្យភាព និងតម្លាភាពក្នុងការបែងចែកផលប្រយោជន៍(ពិន្ទុ៣៥) | | | | | | |

| លក្ខណៈវិនិច្ឆ័យ/លក្ខណៈវិនិច្ឆ័យរង/ សូចនាករ (ពិន្ទុសរុបៈ៣៨៥) | តារាងដាក់ពិន្ទុ | | | | | |
|---|---|---|---|---|---|---|
| | ០ | ១ | ២ | ៣ | ៤ | ៥ |
| *៧.១.តម្លាភាពក្នុងការបែងចែកផលប្រយោជន៍(ពិន្ទុ២០)* | | | | | | |
| មានគោលការបែងចែកផលប្រយោជន៍ | | | | | | |
| រាល់ការសម្រេចចិត្ត ឈរលើលទ្ធផលនៃកិច្ចប្រជុំ | | | | | | |
| បានបិទ និងផ្សព្វផ្សាយព័ត៌មានផ្សេងៗពីការងារពាក់ព័ន្ធនឹង សហគមន៍ | | | | | | |
| គណៈកម្មការសហគមន៍បានដឹងឮពីចំណូលចំណាយ | | | | | | |
| *៧.២.គណនេយ្យភាព(ពិន្ទុ១៥)* | | | | | | |
| មានបញ្ជីកត់ត្រាប្រាក់ចំណូលចំណាយ(ប្រចាំខែ ប្រចាំឆ្នាំ) | | | | | | |
| របាយការណ៍ចំណូលចំណាយប្រចាំឆ្នាំ | | | | | | |
| មានការត្រួតពិនិត្យចំណូលចំណាយពីអ្នកពាក់ព័ន្ធ | | | | | | |
| ៨.គំនិតផ្តួចផ្តើម និងការច្នៃប្រឌិត(ពិន្ទុ៤៥) | | | | | | |
| *៨.១. ការលើកកម្ពស់ជីវភាព និងសុខភាព(ពិន្ទុ២៥)* | | | | | | |
| មានថ្នាលបណ្ដុះកូនឈើរបស់សហគមន៍ | | | | | | |
| បានរៀបចំសួន និងដាំបន្លែនៅតាមផ្ទះសមាជិកសហគមន៍ | | | | | | |
| បានលើកទឹកចិត្ត និងមានការចិញ្ចឹមសត្វតាមគ្រួសារសហគមន៍ | | | | | | |
| បានប្រមូលអនុផលព្រៃឈើ និងប្រើប្រាស់ដោយនិរន្តរភាព | | | | | | |
| បានរៀបចំសហគ្រាសខ្នាតតូច កែច្នៃអនុផលព្រៃឈើឬទេសចរណ៍ធម្មជាតិ | | | | | | |
| *៨.២. ការសន្សំសំចៃទឹក និងថាមពល(ពិន្ទុ២០)* | | | | | | |
| មានយន្តការប្រើប្រាស់ និងគ្រប់គ្រងទឹកក្នុងសហគមន៍ | | | | | | |
| មានមធ្យោបាយត្រងទឹកភ្លៀង ឬ ស្តុកទឹកទុក | | | | | | |

| លក្ខណៈវិនិច្ឆ័យ/លក្ខណៈវិនិច្ឆ័យរង/ សូចនាករ (ពិន្ទុសរុបៈ៣៤៥) | តារាងដាក់ពិន្ទុ | | | | | |
|---|---|---|---|---|---|---|
| | ០ | ១ | ២ | ៣ | ៤ | ៥ |
| មានការប្រើប្រាស់ចង្ក្រានសន្សំសំចៃអុស | | | | | | |
| មានការប្រើប្រាស់ថាមពលព្រះអាទិត្យ | | | | | | |

**៨.តារាងឧបសម្ព័ន្ធ**

១-ប្រកាសទទួលស្គាល់របស់ក្រសួងបរិស្ថាន

២- ផែនទីសហគមន៍តំបន់ការពារធម្មជាតិព្រាំងចំការក្រោម

៣- ផែនទីបែងចែកតំបន់គ្រប់គ្រង

៤-តារាងបញ្ជីឈ្មោះអ្នកចូលរួមពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធថ្នាក់ឃុំ និងសហគមន៍

៥-តារាងបញ្ជីឈ្មោះអ្នកចូលរួមពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធស្រុក និងសហគមន៍